ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ១៨/២០២៦ កបទ.សអ.អរ

<u>សេចក្តីប្រកាសព័ត៌មាន</u>

## លទ្ធផលនៃកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី២ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេសនៃសាធារណរដ្ឋអាមេនី

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦៖ **ឯកឧត្តម មាស គឹមហេង** រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម Mnatsakan Safaryan** អនុរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋអាមេនី បានអញ្ជើញធ្វើជាសហប្រធាននៃកិច្ចពិគ្រោះយោបល់នយោបាយលើកទី២ ប្រកបដោយភាពជោគជ័យ រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេសនៃសាធារណរដ្ឋអាមេនី។

ភាគីទាំងពីរបានសម្តែងនូវការពេញចិត្តចំពោះការរីកចម្រើននៃចំណងមិត្តភាព រវាងប្រទេសទាំងពីរ និងបានកត់សម្គាល់បន្ថែមទៀតថា ឆ្នាំ២០២៧ គឺជាខួបអនុស្សាវរីយ៍លើកទី៣៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។ នេះគឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ដែលឆ្លុះបញ្ចាំងពីមិត្តភាព ការគោរពគ្នាទៅវិញទៅមក ការយោគយល់គ្នា និងតម្លៃរួម ក្នុងរយៈពេលជាង ៣ ទសវត្សរ៍នេះ។

ដោយសង្កត់ធ្ងន់លើសារៈសំខាន់នៃការជំរុញកិច្ចសហប្រតិបត្តិការនយោបាយ និងសេដ្ឋកិច្ច ភាគីទាំងពីរបានពិភាក្សាយ៉ាងស៊ីជម្រៅលើការពង្រឹង និងធ្វើឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត នៃទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរបស់ខ្លួន។ កិច្ចពិភាក្សានេះបានគ្របដណ្តប់លើកិច្ចសហការក្នុងវិស័យសក្តានុពលជាច្រើន រួមមានវិស័យពាណិជ្ជកម្ម និងការវិនិយោគ កសិកម្ម និងកសិ-ឧស្សាហកម្ម អប់រំ ឌីជីថូបនីយកម្ម និងទេសចរណ៍។

ភាគីទាំងពីរបានឯកភាពស្វែងរកកាលានុវត្តភាពនានា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត នៅក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ រួមមាន អាស៊ាន សហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី (EAEU) និងអង្គការសហប្រជាជាតិជាដើម។ ក្នុងន័យនេះ កម្ពុជារង់ចាំស្វាគមន៍គណៈប្រតិភូជាន់ខ្ពស់នៃសាធារណរដ្ឋអាមេនី អញ្ជើញចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ដែលនឹងប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៦។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ភាគីទាំងពីរក៏បានផ្លាស់ប្តូរយោបល់លើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាកង្វល់រួម រួមទាំងបច្ចុប្បន្នភាពលើស្ថានភាពព្រំដែនកម្ពុជា-ថៃ និងបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្ត ក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ ទាំងនៅក្នុងតំបន់ និងលើសកលលោក ក៏ដូចជាការប្រកាន់ខ្ជាប់នូវសណ្តាប់ធ្នាប់អន្តរជាតិដែលផ្អែកលើច្បាប់។

កិច្ចពិគ្រោះយោបល់នយោបាយប្រកបដោយផ្លែផ្កានេះបានបញ្ចប់ទៅ ដោយសហប្រធានទាំងពីរ បានឯកភាពគ្នាកំណត់ពេលវេលាសមស្រប សម្រាប់កិច្ចពិគ្រោះយោបល់នយោបាយជុំបន្ទាប់ នៅសាធារណរដ្ឋអាមេនី ក្នុងពេលឆាប់ៗខាងមុខ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២៦